**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៨៥ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ តាមម្តាយនៅក្នុងពន្ធនាគារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា



៩

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២២១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ១៤៥ អនក្រ.បក ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីវិធាន នីតិវិធី និងយន្តការគ្រប់គ្រងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ តាមម្តាយនៅក្នុងពន្ធនាគារ ដើម្បីចូលរួមលើកកម្ពស់សុខុមាលភាពមាតា និងទារក ព្រមទាំងរួមចំណែកដោះស្រាយកង្វះខាតអាហារូបត្ថម្ភរបស់កូនតាមម្តាយនៅក្នុងពន្ធនាគារ ចាប់តាំងពីកូនក្នុងផ្ទៃ រហូតដល់អាយុ ២ឆ្នាំ សំដៅជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ តាមម្តាយដែលមានសញ្ជាតិខ្មែរនៅក្នុងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

វាក្យសព្ទបច្ចេកទេស ដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

- **ជនជាប់ឃុំ** សំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ។

- **ពន្ធនាគារ** សំដៅដល់កន្លែងប្រើប្រាស់សម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែ។
- **មូលដ្ឋានសុខាភិបាលសាធារណៈ** សំដៅដល់មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព។

## ជំពូកទី២
## ប្រាក់ឧបត្ថម្ភ និងលក្ខខណ្ឌនៃការទទួលផល

**មាត្រា៤.-**

ប្រាក់ឧបត្ថម្ភត្រូវផ្តល់ជូនជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ តាមម្តាយនៅក្នុងពន្ធនាគារ ដែលទទួលសេវាពិនិត្យសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈ ជាដំណាក់កាលដូចខាងក្រោម៖

**ដំណាក់កាលទី១៖** ផ្តល់ការឧបត្ថម្ភចំនួន ៨០ ០០០ **រៀល** ក្នុង **១ដង** ដែលផ្តល់ជាអតិបរមាចំនួន **៤ដង** សម្រាប់ការទទួលសេវាពិនិត្យផ្ទៃពោះមុនពេលសម្រាលកូន។

**ដំណាក់កាលទី២៖** ផ្តល់ការឧបត្ថម្ភនៅពេលសម្រាលតែ **១ដងគត់** ដូចខាងក្រោម៖

- សម្រាលកូនទោល (មួយ) ទទួលបាន ៤០០ ០០០ (**បួនសែន**) **រៀល**
- សម្រាលកូនភ្លោះ (ពីរ) ទទួលបាន ៦០០ ០០០ (**ប្រាំមួយសែន**) **រៀល**
- សម្រាលកូនភ្លោះ (បី) ទទួលបាន ៨០០ ០០០ (**ប្រាំបីសែន**) **រៀល**

ក្នុងករណីសម្រាលកូនភ្លោះចំនួនលើសពីនេះ ទទួលបាន ២០០ ០០០ (**ពីរសែន**) **រៀល** សម្រាប់កូនភ្លោះម្នាក់បន្ថែម។

**ដំណាក់កាលទី៣៖** ផ្តល់ការឧបត្ថម្ភចំនួន ៨០ ០០០ **រៀល** ក្នុង **១ដង** ដែលផ្តល់ជាអតិបរមាចំនួន **១០ដង** ក្នុងនោះ **៣ដង** នៅពេលទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន និង **៧ដង** នៅពេលកូនទទួលថ្នាំបង្ការរហូតដល់កូនអាយុ ២ឆ្នាំ។

**មាត្រា៥.-**

ក្នុងករណីរលូតកូន ប្រាក់ឧបត្ថម្ភនេះត្រូវផ្តល់ ដូចខាងក្រោម៖

- ៨០ ០០០ **រៀល** តែ **១ដង**គត់ ក្នុងករណីគភ៌អាយុក្រោម **១២សប្តាហ៍**
- ៨០ ០០០ **រៀល** ក្នុង **១ដង** ដែលផ្តល់ជាអតិបរមាចំនួន **២ដង** ក្នុងករណីគភ៌អាយុពី**១២សប្តាហ៍** ដល់ **២៤សប្តាហ៍**។

ក្នុងករណីរំលូតកូន ការឧបត្ថម្ភសាច់ប្រាក់ត្រូវបញ្ឈប់ និងត្រូវដាក់ឱ្យចាកចេញពីកម្មវិធី។

ក្នុងករណីកូនស្លាប់ពេលសម្រាល ឬក្រោយពេលសម្រាល ប្រាក់ឧបត្ថម្ភត្រូវបន្តផ្តល់ ដូចខាងក្រោម៖

- ប្រាក់ឧបត្ថម្ភសម្រាប់ការសម្រាលកូននៅតែបន្តផ្តល់ជូនតាមលក្ខខណ្ឌ ដែលបានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ
- ៨០ ០០០ **រៀល** ក្នុង **១ដង** ដែលផ្តល់ជាអតិបរមាចំនួន **៣ដង** នៅពេលម្តាយទទួលសេវាពិនិត្យសុខភាព ក្រោយពេលសម្រាលកូន។

ក្នុងករណីម្ដាយស្លាប់ពេលសម្រាលកូន ឬក្រោយពេលសម្រាលកូន ប្រាក់ឧបត្ថម្ភត្រូវបន្តផ្ដល់ជូនអាណាព្យាបាលស្របច្បាប់ ឬអ្នកដែលមានសិទ្ធិស្របច្បាប់ ឬអ្នកដែលនាំកូនមកទទួលសេវា ដូចខាងក្រោម៖

- ប្រាក់ឧបត្ថម្ភសម្រាប់ការសម្រាលកូននៅតែបន្តផ្ដល់ជូនតាមលក្ខខណ្ឌ ដែលបានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ
- **៨០ ០០០ រៀល** ក្នុង **១ដង** ដែលផ្ដល់ជាអតិបរមាចំនួន **១០ដង** នៅពេលយកកូនមកទទួលសេវាថែទាំសុខភាព និងថ្នាំបង្ការ រហូតដល់កូនអាយុ ២ឆ្នាំ។

ក្នុងករណីស្ត្រីមានផ្ទៃពោះស្លាប់មុនពេលសម្រាលកូន ឬកូនតាមម្ដាយស្លាប់នៅក្នុងពន្ធនាគារ ការឧបត្ថម្ភសាច់ប្រាក់ត្រូវបញ្ឈប់ និងត្រូវដាក់ឱ្យចាកចេញពីកម្មវិធី។

ក្នុងករណីស្ត្រីមានផ្ទៃពោះ ឬម្ដាយដែលទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធី **១ដង** ហើយរួចផុតពីការឃុំខ្លួនក្នុងពន្ធនាគារ ប្រាក់ឧបត្ថម្ភត្រូវបន្តផ្ដល់ជូនតាមលក្ខខណ្ឌ ដែលបានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ រហូតដល់ចប់ **១វគ្គ** នៃការមានផ្ទៃពោះ ដល់កុមារអាយុ ២ឆ្នាំ នៅតាមសហគមន៍រៀងខ្លួន។

**មាត្រា៦.-**

លក្ខខណ្ឌដើម្បីទទួលបានប្រាក់ឧបត្ថម្ភ មានដូចខាងក្រោម៖

- ស្ត្រីមានផ្ទៃពោះត្រូវមានដីកាបង្គាប់ឱ្យឃុំខ្លួន សាលក្រម ឬសាលដីកាស្ថាពរ
- ស្ត្រីមានផ្ទៃពោះបានពិនិត្យផ្ទៃពោះនៅមូលដ្ឋានសុខាភិបាលសាធារណៈយ៉ាងតិច១ដង ដោយមានភ្ជាប់មកជាមួយនូវសៀវភៅសុខភាពមាតាដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ
- ចំពោះកុមារដែលម្ដាយបានចុះឈ្មោះចូលក្នុងកម្មវិធីរួច កុមារនោះត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិដោយភ្ជាប់មកជាមួយនូវបណ្ណសុខភាពកុមារ
- ចំពោះកុមារដែលម្ដាយមិនបានចុះឈ្មោះក្នុងកម្មវិធី កុមារនោះអាចចុះឈ្មោះបាន ដោយត្រូវមានបណ្ណសុខភាពកុមារ ដីកាបង្គាប់ឱ្យឃុំខ្លួន ឬសាលក្រម ឬសាលដីកាស្ថាពររបស់ម្ដាយ និងលិខិតបញ្ជាក់ការស្នាក់នៅតាមម្ដាយ។

ក្នុងករណីប្រធានសក្តិ ដូចជាករណីដែលប្រទេសជាតិទាំងមូល ឬផ្នែកណាមួយជួបវិបត្តិធ្ងន់ធ្ងរដែលមិនអាចអនុញ្ញាតឱ្យដំណើរការអនុវត្តកម្មវិធី និងបំពេញការអនុវត្តលក្ខខណ្ឌបាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវស្នើសុំការលើកលែងការអនុវត្តលក្ខខណ្ឌសម្រាប់កម្មវិធីដោយមានការឯកភាពពីប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា៧.-**

ពន្ធនាគារត្រូវអនុញ្ញាតឱ្យអ្នកទទួលផលអាចរក្សាទុក និងប្រើប្រាស់ប្រាក់ឧបត្ថម្ភរបស់ខ្លួនបានតាមចំនួនប្រាក់ឧបត្ថម្ភនៃកម្មវិធីដែលបានផ្ដល់ជូន។

## ជំពូកទី៣

## តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នដឹកនាំ ក្នុងការអនុវត្តកម្មវិធី

**មាត្រា៨.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គមមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលកិច្ចសហការរវាងក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- ផ្ដល់ការតម្រង់ទិសផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត

- ពិនិត្យតាមដាន វាយតម្លៃ និងផ្តល់យោបល់លើវឌ្ឍនភាពនៃការអនុវត្តកម្មវិធី
- ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធី ជូនរាជរដ្ឋាភិបាល។

**មាត្រា៩.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖
- កំណត់យុទ្ធសាស្ត្រសម្រាប់ការអនុវត្តកម្មវិធី
- គាំទ្រ និងផ្តល់ការណែនាំដល់មូលនិធិជាតិជំនួយសង្គម ក្នុងការរៀបចំផែនការសកម្មភាព និងការអនុវត្តកម្មវិធី
- តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេសនៃកម្មវិធី
- ពិនិត្យ និងស្នើសុំការលើកលែងការអនុវត្តលក្ខខណ្ឌ ក្នុងករណីប្រធានសក្តិ
- ផ្តល់ការណែនាំលើវិធានការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តផ្នែក បច្ចេកទេស នៃកម្មវិធី។

**មាត្រា១០.-**

មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ) ជាប្រតិបត្តិករអនុវត្តកម្មវិធី ដែលមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖
- សម្របសម្រួល និងដឹកនាំការអនុវត្តកម្មវិធី
- រៀបចំលិខិតបទដ្ឋានគតិយុត្ត សៀវភៅប្រតិបត្តិគោលស្តីពីការអនុវត្តកម្មវិធី និងប្រព័ន្ធបច្ចេកវិទ្យា គ្រប់គ្រងព័ត៌មាន សម្រាប់ការគ្រប់គ្រង និងការអនុវត្តកម្មវិធី
- រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ការអនុវត្តកម្មវិធី
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពក្នុងការ អនុវត្តកម្មវិធី
- សម្របសម្រួលការចុះឈ្មោះចូលកម្មវិធី ការអនុវត្តលក្ខខណ្ឌ និងការបើកផ្តល់ នៅក្នុងពន្ធនាគារ
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹង និងព័ត៌មានអំពីការអនុវត្តកម្មវិធី
- តាមដានការអនុវត្តកម្មវិធី កំណត់បញ្ហាប្រឈម និងធ្វើការដោះស្រាយបញ្ហានានា
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគាំពារសង្គម
- ផ្តល់របាយការណ៍ ទិន្នន័យ ព័ត៌មាន និងការបំភ្លឺព័ត៌មាន តាមការស្នើសុំរបស់ក្រុមប្រឹក្សាជាតិ គាំពារសង្គម។

**មាត្រា១១.-**

ក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានពន្ធនាគារ ជាសេនាធិការក្នុងការអនុវត្តកម្មវិធី មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖
- សហការពង្រឹងសមត្ថភាព និងការអនុវត្តតួនាទីរបស់ពន្ធនាគារពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- ផ្តល់ឯកសារសម្រាប់ការចុះឈ្មោះចូលកម្មវិធីដល់ស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ តាមម្តាយនៅក្នុងពន្ធនាគារ



9

- ផ្ដល់ទិន្នន័យស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ តាមម្ដាយនៅក្នុងពន្ធនាគារ ដោយធ្វើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ ជាមួយថ្នាលគ្រប់គ្រងទិន្នន័យ ម.ជ.ជ និងសហការដោះស្រាយរាល់បញ្ហានានាពាក់ព័ន្ធនឹងការធ្វើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ
- ចុះឈ្មោះអ្នកទទួលផលចូលកម្មវិធី បញ្ជូនបន្តពិនិត្យសុខភាព និងសម្របសម្រួលការបើកផ្ដល់ដល់ពន្ធនាគារ
- សម្របសម្រួលការប្រើប្រាស់ប្រាក់ឧបត្ថម្ភរបស់កម្មវិធី នៅក្នុងពន្ធនាគារសម្រាប់អ្នកទទួលផល
- សម្របសម្រួលការដោះស្រាយមតិជំទាស់និងសំណូមពរ និងចូលរួមដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- តាមដាន និងរាយការណ៍ពីការចាកចេញកម្មវិធី
- សហការក្នុងការតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធីនៅពន្ធនាគារ។

**មាត្រា១២.-**

ក្រសួងសុខាភិបាល មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ធានាការផ្ដល់សេវាថែទាំសុខភាព ដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ប្រកបដោយគុណភាព
- តាមដានការបញ្ជូនបន្តពិនិត្យសុខភាព និងបញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព
- ចូលរួមដោះស្រាយមតិជំទាស់និងសំណូមពរ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- សហការក្នុងការតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធី។

**មាត្រា១៣.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ ផ្ដល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់ការអនុវត្តកម្មវិធី
- វិភាជថវិកា ពិនិត្យ និងផ្ដល់យោបល់លើរបាយការណ៍អនុវត្តថវិកា
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**មាត្រា១៤.-**

ក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ និងផ្ដល់យោបល់ ដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងកុមារនៅក្នុងពន្ធនាគារ
- ចូលរួមផ្សព្វផ្សាយការយល់ដឹងអំពីការចិញ្ចឹមកូនតាមបែបវិជ្ជមាននៅក្នុងពន្ធនាគារ
- ចូលរួមផ្ដល់យោបល់ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- ចូលរួមតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។

## ជំពូកទី៤
## ថវិកាអនុវត្តកម្មវិធី

**មាត្រា១៥.-**

រាល់ចំណាយលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម២ឆ្នាំ តាមម្ដាយនៅក្នុងពន្ធនាគារ ត្រូវហិរញ្ញប្បទានដោយថវិការដ្ឋ តាមរយៈមូលនិធិហិរញ្ញប្បទានគាំពារសង្គម។



9

**មាត្រា១៦.-**

ការទូទាត់ចំណាយលើការឧបត្ថម្ភកម្មវិធីនេះ ក្នុង ១វគ្គ នៃការមានផ្ទៃពោះ រហូតដល់កុមារអាយុ ២ឆ្នាំ សម្រាប់ជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនតាមម្តាយនៅក្នុងពន្ធនាគារ មិនត្រូវលើសពី **១ ៥២០ ០០០ រៀល** លើកលែងករណីសម្រាលកូនភ្លោះ។

## ជំពូកទី៥
## របាយការណ៍ និងការចុះពិនិត្យការអនុវត្តកម្មវិធី

**មាត្រា១៧.-**

ម.ជ.ជ. ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជូនក្រុមប្រឹក្សាជាតិគាំពារសង្គម តាមកាលកំណត់ដូចខាងក្រោម៖

- របាយការណ៍ប្រចាំត្រីមាសត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ។
- របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ។

ក្នុងករណីចាំបាច់ ម.ជ.ជ. ត្រូវផ្តល់របាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីតាមសំណើរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា១៨.-**

ម.ជ.ជ. ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្តីពីការអនុវត្តកម្មវិធី ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងត្រូវចម្លងជូនក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងត្រីមាសទី១ នៃឆ្នាំបន្ទាប់។

ការអនុវត្តកម្មវិធីនេះត្រូវស្ថិតនៅក្រោមអធិការកិច្ច និងសវនកម្មអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៩.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម មានសិទ្ធិចាត់តាំងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ចុះពិនិត្យ និងសង្កេតជាក់ស្តែងដល់ទីកន្លែងអំពីការអនុវត្តកម្មវិធី។

## ជំពូកទី៦
## ការដោះស្រាយវិវាទ ឬបណ្តឹង

**មាត្រា២០.-**

វិវាទ ឬបណ្តឹង ដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ត្រូវដោះស្រាយក្នុងកម្រិត ម.ជ.ជ.។ រាល់វិវាទ ឬបណ្តឹង ដែលមិនអាចដោះស្រាយបានតាមយន្តការសម្របសម្រួលក្នុងកម្រិតប្រតិបត្តិករកម្មវិធី ភាគីណាមួយនៃវិវាទ ឬបណ្តឹង អាចប្តឹងបន្តទៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គមដើម្បីសម្របសម្រួលដោះស្រាយ មុនពេលប្តឹងទៅតុលាការ។

យន្តការ និងនីតិវិធីនៃការសម្របសម្រួលដោះស្រាយវិវាទនៃការអនុវត្តកម្មវិធី នៅកម្រិត ម.ជ.ជ. ត្រូវកំណត់នៅក្នុងសៀវភៅប្រតិបត្តិគោលស្តីពីការអនុវត្តកម្មវិធី។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



ƍ

**មាត្រា២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីគ្រប់ក្រសួង អគ្គនាយកនៃមូលនិធិជាតិជំនួយសង្គម អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច**
**អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ជា សុមេធី**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ